ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៤៧/២៤ គ.ជ.ប.ជ

# របាយការណ៍ត្រីមាសទី៤
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅត្រីមាសទី១ ឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្ដាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្សី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្ដាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្ដាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្ដៅ និងផ្ដល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្ដល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្ដល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
- បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្ស៊ិក។

### ខ. ការបង្ការ ទប់ស្កាត់

**១. តាមរយៈការលើកកម្ពស់ការយល់ដឹង**

១.១. ការអប់រំដោយផ្ទាល់

១.១.១. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិនិងអន្តរជាតិ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣ ក្រោមប្រធានបទស្តីពី «បច្ចេកវិទ្យាជាមធ្យោបាយដើម្បីអភិវឌ្ឍជាតិ មិនមែនដើម្បីជួញដូរមនុស្ស» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ និងលោកជំទាវ** ដោយមានការចូលរួមពីថ្នាក់ដឹកនាំសំខាន់ៗ ក្នុងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានាប្រចាំកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជិត និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សសរុបប្រមាណ ៣.២០០អង្គ/នាក់។

- លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចំនួន ០៨ រួមមាន៖ ខេត្តកណ្តាល ត្បូងឃ្មុំ ស្វាយរៀង កំពង់ធំ កោះកុង សៀមរាប ព្រៃវែង និងខេត្តឧត្តរមានជ័យ បានសហការជាមួយអង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣ ក្រោមប្រធានបទ «**បច្ចេកវិទ្យាជាមធ្យោបាយដើម្បីអភិវឌ្ឍជាតិ មិនមែនដើម្បីជួញដូរមនុស្ស**» និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបប្រមាណ **៤.៧៦២**អង្គ/នាក់ (ស្រី **២.០៩១**នាក់)។

១.១.២. កម្មវិធីដង្ហែរព្យុហយាត្រា

- ខេត្តសៀមរាប៖ រដ្ឋបាលខេត្ត បានសហការជាមួយគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការមូលនិធិអេ២១ រៀបចំប្រារព្ធកម្មវិធីព្យុហយាត្រាឆ្ពោះទៅបញ្ឈប់អំពើជួញដូរមនុស្ស លើកទី២ ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានចូលរួមពី មន្ត្រីរាជការស៊ីវិល កងកម្លាំងនគរបាល កងរាជអាវុធហត្ថ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស យុវជនកាយរិទ្ធ យុវជនកាកបាទក្រហម បុគ្គលិកអង្គការសមាគម ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិ សរុបប្រមាណ **៦១០**នាក់(ស្រី **៣៣៣**នាក់)។

១.១.៣. ការផ្សព្វផ្សាយអប់រំ និងវេទិកាសាធារណៈ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៣នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរ អង្គភាពពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើ ចំណាកស្រុកដោយសុវត្ថិភាព វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **៤០.៦៩៥**លើក មានអ្នកចូលរួមសរុបចំនួន **២.៣៣០.៣៦២**នាក់ ស្ត្រីចំនួន **១.២១១.៦១៥**នាក់ (ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ មានចំនួន **១.៦៧៧.៦០៦**នាក់ កើនឡើងចំនួន **៦៥២.៧៥៦**នាក់) ស្មើនឹង **៣៨,៩០%** ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការផ្សព្វផ្សាយអប់រំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៦១៦ | ៦១.១១២ | ៣១.០៧៦ | ១.៧៦៨ | ៦៩.២៣១ | ៣៧.៣៥៣ |
| | សរុប ក្រសួង ស្ថាប័ន | ៦១៦ លើក | ៦១.១១២ នាក់ | ៣១.០៧៦ នាក់ | ១.៧៦៨ លើក | ៦៩.២៣១ នាក់ | ៣៧.៣៥៣ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ២.៣៤៣ | ១៧០.៣៧៩ | ៧៧.៤០៦ | ៤.២០៦ | ២៤៧.៧១៥ | ១៣៣.៥៤៣ |
| ៣ | ខេត្តបាត់ដំបង | ២.៤៧១ | ១៣៤.១២០ | ៧២.៤៤២ | ១.៨៤៧ | ៦៥.៥២០ | ៣៦.១៨០ |
| ៤ | ខេត្តពោធិ៍សាត់ | ១.៨៨៥ | ២១០.២៥៨ | ១១៣.៣៣៥ | ៥១៣ | ១៨.៦៧៥ | ១០.១១៣ |
| ៥ | ខេត្តសៀមរាប | ១.៦៣៩ | ១៥៧.៩៩៥ | ៩៧.០០៦ | ៦១៧ | ២៩.៧៦៦ | ១៦.៣៩១ |
| ៦ | ខេត្តកំពង់ឆ្នាំង | ២.២២៧ | ៦២.៦៨០ | ៣២.៥៧៩ | ១.១៧៥ | ៣៣.៦៨៧ | ១៧.៣០៦ |
| ៧ | ខេត្តកំពង់ចាម | ៥.៦៣៧ | ៣៦៩.៤៧១ | ១៧៨.៦៥៨ | ១៧៥ | ៣.៧៦៥ | ១.៩៧៤ |
| ៨ | ខេត្តព្រះសីហនុ | ៣០៥ | ១២.២៣៨ | ៥.៥១៨ | ១៨ | ៩៦៥ | ៥០១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩ | ខេត្តព្រះវិហារ | ៣៤ | ៦.៦៦៦ | ៣.៥០៩ | ៨ | ២.២៧៩ | ៧៦២ |
| ១០ | ខេត្តស្វាយរៀង | ៦ | ៥៨ | ៣៤ | ១១៤៣ | ៤៩.៩០៩ | ២៨.៣៨១ |
| ១១ | ខេត្តប៉ៃលិន | ១០៣ | ២.៧០៦ | ៧៣៣ | ៨៣ | ២.៩៣០ | ៧៣៧ |
| ១២ | ខេត្តកោះកុង | ២ | ៣០០ | | ៣០៩ | ៧.៦៦៦ | ៣.៧៤៩ |
| ១៣ | ខេត្តកំពត | ៤១ | ១.០០៤ | ៦១០ | ២០ | ៦៦០ | ៤៥០ |
| ១៤ | ខេត្តកំពង់ធំ | ២.១០៥ | ៣០៨.៨២៣ | ១៦២.៩៦០ | ១៥៨ | ១៤.២៧១ | ៥.០៦៨ |
| ១៥ | ខេត្តតាកែវ | ១.២០៥ | ៤៣.៥៧២ | ២២.៩២៤ | ៥៣៦ | ១៨.៤៥៥ | ៤.៩៩២ |
| ១៦ | ខេត្តក្រចេះ | ៥៤ | ២.៨៥៦ | ១.៦៧៥ | | | |
| ១៧ | ខេត្តកែប | ២៩ | ៥.១២៦ | ២.៩៦៤ | ១០១ | ៥.៥៤៦ | ៣.២០៤ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៣៥២ | ២៧.៩៨៧ | ១៣.០៣៤ | ១០ | ១.៥២០ | ៨៧៦ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៥២៨ | ៤៨.៤៧២ | ២៤.៧៦១ | ៣៧ | ២.២០១ | ១.២៩៨ |
| ២២ | ខេត្តត្បូងឃ្មុំ | ៣.៩៧៦ | ៦៥.៨៨១ | ៣២.៣២៨ | ១៩៣ | ៥.៥៨០ | ២.៣៧៥ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១.៥៣៣ | ៣៩.៤៩៤ | ២២.០៧៨ | ៥០០ | ១៣.៣៩៦ | ៧.៩៣៥ |
| ២៤ | ខេត្តឧត្តរមានជ័យ | ២ | ១.៨០៣ | ១.២៣៦ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១៨៥ | ៣.៦២៤ | ១.៥៦១ | | | |
| សរុប រាជធានី-ខេត្ត | | ២៦.៦៦២លើក | ១.៦៧៥.៥១៣នាក់ | ៨៦៧.៣៥១នាក់ | ១១.៦៤៩លើក | ៥២៤.៥០៦នាក់ | ២៧៥.៨៣៥នាក់ |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>៤០.៦៩៥ លើក | | ចំនួនមនុស្ស<br>២.៣៣០.៣៦២ នាក់ | | ចំនួនស្ត្រី<br>១.២១១.៦១៥ នាក់ | |

### ១.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកំពង់ចាម៖**
  - ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី នៃស្នងការដ្ឋាននគរបាលខេត្ត បានចុះផ្សព្វផ្សាយអនុក្រឹត្យលេខ ១៨៣ អនក្រ.បកស្តីពី ការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេស នៅស្រុកជើងព្រៃ និងកំពង់សៀម អ្នកចូលរួមចំនួន **២១.៨៤១**នាក់ (ស្រី **២.៤៤០**នាក់)។
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរៀបចំកម្មវិធីផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព លក្ខខណ្ឌការងារតាមរដូវកាល និងសុខភាពសុវត្ថិភាពការងារ ដល់បេក្ខជន ពលករ និងក្រុមគ្រួសារ អ្នកចូលរួមចំនួន **៣០២**នាក់ (ស្រី **៧៨**នាក់)។
- **ខេត្តកំពង់ឆ្នាំង៖**
  - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈកិច្ចតាមប្រព័ន្ធអនឡាញ របស់មន្ទីរ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្សនៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនចំនួន ០៨លើក។
  - ស្រុកទឹកផុស បានចុះផ្សព្វផ្សាយច្បាប់ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ដល់គណៈបញ្ជាការឯកភាពស្រុក ចំនួន **០៦**លើក អ្នកចូលរួមចំនួន **១១៧**នាក់ (ស្រី **១៩**នាក់)។
  - ស្រុកសាមគ្គីមានជ័យ បានផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស កាធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈកិច្ចប្រជុំ គ.ក.ស.ក អ្នកចូលរួមចំនួន **២២**នាក់ (ស្រី **១៣**នាក់)។

- **ខេត្តកណ្តាល៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយស្តីពី ការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំបូកសរុបការងារដល់លោក លោកស្រី ថ្នាក់ដឹកនាំមន្ទីរ ប្រធានការិយាល័យ លោកនាយក នាយិកា នៃគ្រឹះស្ថានមធ្យមសិក្សាទូទាំងខេត្ត ចំនួន ០៤លើក អ្នកចូលរួមចំនួន **៤៧៦**នាក់ (ស្រី១២៨នាក់)។
- **ខេត្តព្រះសីហនុ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយមន្ទីរកិច្ចការនារីខេត្ត និងអាជ្ញាធរមូលដ្ឋានស្រុក/ក្រុង បានគាំទ្រអ្នកស្ម័គ្រចិត្តភូមិ ផ្សព្វផ្សាយឧបករណ៍សកល(កម្រិត១) ស្តីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ ការចិញ្ចឹមកូនបែបវិជ្ជមាន និងសុខភាពភ្នែក ដោយបានបញ្ជ្រាបការអប់រំ អំពីជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០៣លើក អ្នកចូលរួមចំនួន **៧១៣**នាក់ (ស្រី ៤៩០នាក់)។
- **ខេត្តកំពត៖** បានផ្សព្វផ្សាយការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅស្រុកដងទង់ និងស្រុកឈូក ចំនួន **៣៤**លើក អ្នកចូលរួមចំនួន **២៧៥**នាក់ ស្រី **១៧២**នាក់។
- **ខេត្តប៉ៃលិន៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានផ្សព្វផ្សាយស្តីពី ភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ តាមរយៈកិច្ចប្រជុំជាមួយការិយាល័យជំនាញចំណុះមន្ទីរ គណៈគ្រប់គ្រងសាលារៀន ដើម្បីត្រៀមរៀបចំបើកបវេសនាកាលឆ្នាំសិក្សាថ្មី២០២៣-២០២៤ អ្នកចូលរួមចំនួន **៥៨៥**នាក់ (ស្រី **៣២៧**នាក់)។
- **ខេត្តបន្ទាយមានជ័យ៖**
  - **មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍៖** បានធ្វើការផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **១.០៥៥**នាក់ (ស្រី **៨១៤**នាក់) អតីតពលករចំនួន **៣០៨**នាក់ (ស្រី **២៤៣**នាក់)។
  - **អង្គការកល្យាណមិត្ត៖** កម្មវិធីអប់រំផ្សព្វផ្សាយបំណិនជីវិត ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសម្ភារៈអនាម័យប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **៧៩៦**នាក់។
  - **អង្គការតំណក់ទឹកសាខាប៉ោយប៉ែត៖**
    - បានចុះធ្វើសកម្មភាពបណ្ណាល័យចល័ត អប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **២៨១**នាក់ (ស្រី **១៥០**នាក់)។
    - សកម្មភាពប្រជុំលើកកម្ពស់ការយល់ដឹងដល់ក្រុមយុវជន និងគ្រួសារ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួមចំនួន **៣៧**នាក់ (ស្រី **២៨**នាក់)។
  - **អង្គការសាម៉ារីតាន់ភឺស** បានអប់រំសហគមន៍អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំនួន **៣៨៥**នាក់ (ស្រី **១១៨**នាក់) កុមារ **៣៧**នាក់ (កុមារី **១០**នាក់)។
  - **អង្គការអន្តរជាតិទេសន្តរប្រវេសន៍៖**
    - បានធ្វើការផ្តល់វគ្គតម្រង់ទិស ស្តីពីធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាពដល់ពលករចំនួន **៩៤៣**នាក់ (ស្រី **២៨៣**នាក់) កុមារ **៥២**នាក់។
    - បានប្រឹក្សាយោបល់ដោយផ្ទាល់ជាលក្ខណៈឯកជន ជាមួយពលករវិលត្រលប់ មានដូចជា៖ ១-ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពចំនួន **៣១**នាក់ (ស្រី **០៨**នាក់)។ ២-ឱកាសទទួលបានការងារក្នុងស្រុកចំនួន **២៣**នាក់ (ស្រី **០២**នាក់)។

### ១.១.៥. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ) | ០១ | ១១០ | ៩០ |
| ២ | អង្គការមូលនិធិអេ២១(ខេត្តសៀមរាប) | ២៦ | ២.៧៧១ | ១.៧៧៨ |
| ៣ | អង្គការសាម៉ារីតាន់ភឺស(ខេត្តបាត់ដំបង) | ០៣ | ៤.៩២១ | ២.៧៧១ |
| ៤ | អង្គការប្រភពទឹកនៃសេចក្តីសង្ឃឹម(ខេត្តត្បូងឃ្មុំ)<br>អង្គការសពម្ព័ន្ធចាប់ដៃ (ខេត្តត្បូងឃ្មុំ) | ០១<br>០១ | ១៨៥<br>២៣៥ | ៤៩<br>១៦២ |
| ៥ | សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍(ខេត្តតាកែវ) | ០១ | ១០០ | ១០០ |
| | សរុប | ៣៣ លើក | ៨.៣២២ នាក់ | ៤.៩៥០ នាក់ |

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន ១០.៥១០ដង។
- **លេខាធិការដ្ឋាន គ.ខ.ប.ជ** ផ្សព្វផ្សាតាមប៉ុស្តិ៍វិទ្យុ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសរុបចំនួន **៧៨០**លើក មានខេត្តៈ (សៀមរាប **៣៧៧**លើក ព្រៃវែង **១៥០**លើក ត្បូងឃ្មុំ **១៨០**លើក កំពង់ឆ្នាំង **៦០**លើក ប៉ៃលិន ០៨លើក កំពង់ចាម ០៥លើក)។
- **ខេត្តបន្ទាយមានជ័យៈ អង្គការអន្តរជាតិទេសន្តរប្រវេសន៍** ពលករដែលទទួលបានព័ត៌មានពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព នៅសហគមន៍ចំនួន **៣២៩**នាក់ (ស្រី **២៥០**នាក់) និងប្រឹក្សាជាលក្ខណៈឯកជនភាពតាមរយៈទូរស័ព្ទ និងប្រព័ន្ធបណ្តាញសង្គមចំនួន **៦៦**នាក់ (ស្រី **២០**នាក់)។

### ១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សៈ**
  - លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនចំនួន ០៤លើក (១).ក្នុងសិក្ខាសាលាស្តីពី ការពង្រឹងអក្ខរាវិទ្យុ ក្រមសីលធម៌លើវេទិកា ឬផ្សាយផ្ទាល់ និងឈ្វេងយល់ពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងគ្រឿងញៀន។ (២).កម្មវិធីសំឡេងពលរដ្ឋស្តីពីការទប់ស្កាត់អំពើជួញដូរស្ត្រី និងក្មេងស្រី នៅវិទ្យុស្ត្រី។ (៣).សិក្ខាសាលាស្តីពី តួនាទី នៃវិស័យវប្បធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។(៤).កម្មវិធី "Grow Under Peace" របស់ស្ថានីយ៍ទូរទស្សន៍កម្ពុជាថ្មី គឺជាវេទិកាសម្រាប់ថ្នាក់ដឹកនាំសំខាន់ៗ ធ្វើការចែករំលែកនូវបទពិសោធន៍ជីវិត និងបទពិសោធន៍ការងារ ក្នុងភាពជាអ្នកដឹកនាំ។
  - ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាអ្នកសារព័ត៌មានស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូមនុស្សចំនួន ០១លើក។
- **ខេត្តកំពង់ចាមៈ** (១).**តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមធ្វើបទបង្ហាញស្តីពីយន្តការដោះស្រាយពាក្យបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍ និងការចែករំលែកបទពិសោធន៍ល្អក្នុងការអនុវត្ត ចំនួន ០១លើក គាំទ្រដោយអង្គការអន្តរជាតិការងារ។ **២.ក្រុមការងារជំនាញនៃ គ.ខ.ប.ជ** បានចូលរួមជាវាគ្មិនកម្មវិធីសន្ទនាមតិ នៅវិទ្យុជាតិនៃមន្ទីរពត៌មានខេត្ត ចំនួន ០៩លើក។

## ១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ (IEC)

- **ខេត្តត្បូងឃ្មុំ៖** ក្រុមជំនាញទាំង០៦ នៃលេខាធិការដ្ឋាន គ.ខ.ប.ជ ធ្វើការចងបដាពាក្យស្លោកចំនួន ២០ពាក្យស្លោក នៅកន្លែងអុំទូក ស្តង់តាំងពិពណ៌ កន្លែងប្រជុំតន្ត្រី និងបានណែនាំ ទូរទស្សន៍ និងវិទ្យុជាតិត្បូងឃ្មុំ ធ្វើការផ្សព្វផ្សាយ និងដាក់ពាក្យស្លោករត់លើកអេក្រង់ពេលកំពុងផ្សាយផ្ទាល់ ក្នុងឱកាសពិធីបុណ្យអុំទូក។
- **ខេត្តព្រៃវែង៖** ក្រុមការងារលេខាធិការដ្ឋាន បានចងបដាអប់រំ អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងពីធីអុំអូក ដែលរៀបចំដោយរដ្ឋបាលខេត្ត មានអ្នកទស្សនាចំនួន **៧៦.៥០១**នាក់។
- **ខេត្តកណ្តាល៖** គ.ខ.ប.ជ បានរៀបចំផ្សព្វផ្សាយ និងចងបដាផ្សព្វផ្សាយ ពាក់ព័ន្ធទៅនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន **១៥**បដា នៅតាមបរិវេណប្រារព្ធពិធីប្រណាំងទូក នៅក្រុងតាខ្មៅ ខេត្តកណ្តាល។
- **ខេត្តកំពង់ធំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានចងបដាពាក្យស្លោកចំនួន **១០**បដា ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ក្នុងពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ។
- **ខេត្តស្ទឹងត្រែង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការផ្សព្វផ្សាយអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋក្នុងពិធីរៀបចំបុណ្យអុំទូក អកអំបុក សំពះព្រះខែ ចំនួន **១០**បដា។
- **ខេត្តសៀមរាប៖**
  - **រដ្ឋបាលស្រុកពួក** បានធ្វើការចែកខិតប័ណ្ណអំពីការធ្វើចំណាកស្រុក ចំនួន **១៥.៦២១**ខិតប័ណ្ណ។
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** បានផ្តល់សៀវភៅកម្រងព័ត៌មានសេវាស្តីពី អំពើហិង្សាលើពលករចំណាកស្រុកជាស្ត្រីនៅអាស៊ាន ដល់រដ្ឋបាលស្រុកពួក បានចំនួន **៥០០**ក្បាល ដើម្បីធ្វើការចែកជូន និងផ្សព្វផ្សាយជូនប្រជាពលរដ្ឋបន្ត។
  - វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បានចែកខិតប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជ្រើសរើសបេក្ខជនចូលរៀនជំនាញវិជ្ជាជីវៈ ចំនួន **៣ ៧១៦**ខិតប័ណ្ណ។
- **ខេត្តបន្ទាយមានជ័យ៖**
  - **ក្រុមការងារ(គ.ខ.ប.ជ)៖** បានរៀបចំចងបដាពាក្យស្លោកពាក់ព័ន្ធនឹង ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅបរិវេណសួនមានជ័យ ចំនួន០៦បដា។
  - **អង្គការសាម៉ារីតាន់ភឺស** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃចំនួន **៤.០៥៣**នាក់(ស្រី**២.៣២០**នាក់) កុមារ **៣៥៣**នាក់ (កុមារី **២៦៨**នាក់)។
- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស៖**
  - បានចែកខិត្តប័ណ្ណស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **១៦.០៦៩**សន្លឹក ខិត្តប័ណ្ណទប់ស្កាត់អំពើជួញដូរមនុស្សចំនួន **១.៥៤២**សន្លឹក និងខិត្តប័ណ្ណអប់រំពីការពារការរំលោភបំពានកុមារ តាមប្រព័ន្ធអនឡាញចំនួន **៦០០**សន្លឹក។
  - ចែកអាវយឺតភ្ជាប់ជាមួយសារអប់រំស្តីពី ចំការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់យុវជន និងអាណាព្យាបាល សរុបចំនួន **១០៩**នាក់ (ស្រី **៦០**នាក់) កុមារ **៣៤**នាក់។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរ ចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៨១.១៦២នាក់(ស្រី ៨០.៣៦៧នាក់) អនីតិជន ៣.៤៦៨នាក់(ស្រី ១.២៧៧នាក់)៖
  - ស្របច្បាប់ ចំនួន ១៤០.៧៥០នាក់ (ស្រី ៦៤.៦៥១នាក់) អនីតិជន ៣០៦នាក់ (ស្រី ៩៣នាក់)។
  - មិនស្របច្បាប់ចំនួន៣៩.៧៣៦នាក់(ស្រី១៥.៤២៧នាក់)អនីតិជន៣.០៤៥នាក់(ស្រី១.១៤៤នាក់)។
  - ដាច់ការទាក់ទងចំនួន ៦៧៦នាក់(ស្រី ២៨៩នាក់) អនីតិជន ១៣៥នាក់(ស្រី៤០នាក់)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ៥៩.២៨៧នាក់ (ស្រី ២៩.៩៤០នាក់) អនីតិជន ២៣៣នាក់(ស្រី ៨៩នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន០៣ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ខេត្តបន្ទាយមានជ័យចំនួន ០៣លើក មនុស្សចំនួន ០៦នាក់ (ស្រី ០១នាក់) បាត់ដំបងចំនួន ០១លើក មនុស្សចំនួន ០៥នាក់ (ស្រី ០៣នាក់) និងខេត្តព្រះវិហារចំនួន០១លើក មនុស្សចំនួន ០៥នាក់ (ស្រី ០២នាក់) រួចបានធ្វើកិច្ចសន្យាអប់រំ ណែនាំរួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

### ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កំពត កោះកុង ក្រចេះ ព្រះវិហារ ព្រៃវែង និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ៧៣លើក។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ កំពង់ឆ្នាំង ស្វាយរៀង និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យា ហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ១៣៣គោលដៅ មនុស្សចំនួន ៥៦៣នាក់ ស្រី៤២៤នាក់។

### ២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ចំនួន ៥៣៧នាក់ (ស្រី៣២នាក់) និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូល តែមួយចំនួន ៥៣៧នាក់(ស្រី២៧នាក់) បានទំនាក់ទំនងសួរសុខទុក្ខនារីខ្មែរ រៀបការទៅរស់នៅប្រទេសចិនចំនួន ០៩នាក់។

## ៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ចំនួន ១.១៣៣នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៤០ករណី (ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ មានចំនួន ៣៧ករណី មានការកើនឡើងចំនួន ០៣ករណី) ស្មើនឹង ៨,១០% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្តចំនួន ៥០នាក់ (ស្រី ១០នាក់) ជនសង្ស័យជាអនីតិជន ០៥នាក់ និងជាជនបរទេស ០២នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ៨៨នាក់ (ស្រី ៨៥នាក់) អាយុក្រោម១៥ឆ្នាំ ៣០នាក់ អាយុ១៥-១៧ឆ្នាំ ១៥នាក់ និងអាយុ១៨ឆ្នាំឡើង ៤៣នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ៥១នាក់ និងប្រគល់ឱ្យគ្រួសារ ៣៧នាក់) ក្នុងនោះចែកជា៖

ក. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៤ករណី/១០ករណី (ថយចុះ ០៦ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៧នាក់(ស្រី០១នាក់) ជាជនបរទេស ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៣នាក់ (ស្រី ១០នាក់) អាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ ១៥-១៧ឆ្នាំ ០៥នាក់ និងអាយុ១៨ឆ្នាំឡើង ០៧នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៧នាក់ និងគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ០១ | ០៥ | ០១ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | ០៣ | |
| -អំពើលក់-ដូរមនុស្សសម្រាប់ឆ្លងដែន | ០១ | ០៦ | ០២ | ស៊ីស០១ |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | ០១ | |
| *សរុប* | *០៤ ករណី* | *១៣ នាក់* | *០៧ នាក់* | *០១ នាក់* |

ខ. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៣៦ករណី/២៧ករណី (កើនឡើង ០៩ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៤៣នាក់(ស្រី ០៩នាក់) ជនសង្ស័យជាអនីតិជន ០៥នាក់ និងជាជនបរទេស ០១នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ៧៥នាក់ (ស្រី ៧៥នាក់) អាយុក្រោម១៥ឆ្នាំ ២៩នាក់ អាយុ១៥-១៧ឆ្នាំ ១០នាក់ និងអាយុ១៨ឆ្នាំឡើង ៣៦នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ៤៤នាក់ និងគ្រួសារចំនួន ៣១នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | បរទេស |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោស( ការចាប់ពង្រត់ ការឃុំឃាំង ឬបង្ខាំង | ០១ | ០២ | ០១ | វៀតណាម១ |
| -សញ្ជារកម្ម | ០២ | ១០ | ០៣ | |
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០២ | ០៨ | ០៣ | |
| -សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៤ | ២៦ | ០៦<br>(អនី.០២) | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០៤ | ០៤ | ០៥ | |

| | | | | |
|---|---|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៥ | ១៥ | ១៦ (អនី.០២) | |
| -អំពើអាសប្រាតនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៨ | ១០ | ០៩ (អនី.០១) | |
| *សរុប* | *៣៦ ករណី* | *៧៥ នាក់* | *៤៣ នាក់* | *០១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស និងក្នុងស្រុកសរុបចំនួន ៣៥នាក់(ស្រី០៧នាក់) ៖
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ
    - បានទទួលចំនួន ៣០នាក់ (ស្រី១៥នាក់) មកពីប្រទេសចិន ២៥នាក់ និងប្រទេសម៉ាឡេស៊ី ០៥នាក់ បានសម្ភាសន៍កំណត់អត្តសញ្ញាណបឋម ដើម្បីផ្តល់សេវាសមស្របចំនួន ៣០នាក់ (ករណីអាពាហ៍ពិពាហ៍ ផ្ទុយពីធន្ទ:/បង្ខំ ២៥នាក់ ជួញដូរកម្លាំងពលកម្ម ០៥នាក់ និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
    - បានទទួលពីនគរបាលមានសមត្ថកិច្ចនៅក្នុងស្រុកចំនួន ០៥នាក់(ស្រី០២នាក់) ជាករណីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។
- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់ពីប្រទេសចិន ចំនួន ៦១នាក់(ស្រី ៥៨នាក់)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ ផ្ទុយពីធន្ទៈទៅចិន ៥០នាក់ ស្នាក់នៅដោយខុសច្បាប់ ១០នាក់ (ចិន ០៧នាក់ ម៉ាឡេស៊ី ០៣នាក់) និងកេងកម្លាំងពលកម្ម ០១នាក់ ម៉ាឡេស៊ី។
  - កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ វៀតណាម និងឡាវបញ្ជូនត្រឡប់មកវិញចំនួន ៦៦លើក មនុស្សចំនួន ៩៩៧នាក់ (ស្រី ២៧៦នាក់) អនីតិជន ៩៤នាក់ (ស្រី ៥៩នាក់) ក្នុងនោះមាន៖
    - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យចំនួន ៤៦លើក មនុស្ស ៩១៥នាក់ (ស្រី ២៣៣នាក់) អនីតិជន ៦៥នាក់ (ស្រី ២៦នាក់)
    - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀងចំនួន ០៥លើក មនុស្ស ៤៩នាក់ (ស្រី ២៩នាក់) អនីតិជន ២៩នាក់ (ស្រី ៣៣នាក់)
    - ស្នងការដ្ឋាននគរបាលខេត្តកោះកុងចំនួន ១៣លើក មនុស្ស ២១នាក់ (ស្រី ០២នាក់)
    - ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែងចំនួន ០២លើក មនុស្ស ១២នាក់(ស្រី)។

### ២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស

ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា នៅអង្គការការីតាស់កម្ពុជា ហាការ អាដហុក រតនៈអ៊ីនធីណេសិនណល និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) សរុបចំនួន ៣០នាក់(ស្រី០៥នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត(គ.រ.ប.ដ/គ.ខ.ប.ដ) បានសហការជាមួយ អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលចំនួន ៣០វគ្គ មានសិក្ខាកាមចូលរួមចំនួន **១.៥៣៦**នាក់ ក្នុងនោះមានស្ត្រី ៩៦៥នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិកគ.រ.ប.ដ/គ.ខ.ប.ដ។

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ដ | ០៩ | ៣២៦ | ១០៣ |
| ២ | ខេត្តស្វាយរៀង | ១៣ | ២៦៥ | ១៧៤ |
| ៣ | ខេត្តសៀមរាប | ០៨ | ២៥០ | ១៤១ |
| ៤ | ខេត្តពោធិ៍សាត់ | ០២ | ៧៧ | ៤៨ |
| ៥ | ខេត្តព្រះវិហារ | ០១ | ២៨ | ០៣ |
| ៦ | ខេត្តព្រៃវែង | ០១ | ២៨ | ០០ |
| ៧ | ខេត្តក្រចេះ | ០១ | ៥៩ | ១៦ |
| ៨ | ខេត្តបាត់ដំបង (អង្គការសាម៉ារីតាន់ភឺស) | ១០ | ២.០៥២ | ៩៣៦ |
| សរុប | | ៤៥ វគ្គ | ២.២០១ នាក់ | ១.៣៦៥ នាក់ |

#### ២.សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការធ្វើបច្ចុប្បន្នភាពកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម អំពីនីតិវិធីប្រតិបត្តិការបទដ្ឋាន (SOP) ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរ សណ្ឋាគារ បាវ៉ាឌីសខេត្តសៀមរាប។
- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ដ បានអញ្ជើញជាអធិបតី៖
  - ក្នុងសិក្ខាសាលាថ្នាក់ជាតិ ការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) និងការបង្កើតផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០២៤-២០២៨) ដោយមានការចូលរួមពី តំណាងក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ដ និងអង្គការដៃគូពាក់ព័ន្ធ សរុបចំនួន **១០២**នាក់ (ស្រី **៤៧**នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។
  - ក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីយន្តការណ៍បញ្ជូនបន្តថ្នាក់ជាតិ សម្រាប់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពី ព្រះរាជអាជ្ញារង នៃអយ្យការ អមសាលាដំបូងរាជធានី

ភ្នំពេញ តំណាងក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គការដៃគូពាក់ព័ន្ធសរុបចំនួន ៥៤នាក់ (ស្រី ២១នាក់) ឧបត្ថម្ភគាំទ្រដោយ អង្គការ IOM នៅសណ្ឋាគារ កាំបូឌីយ៉ាណា។

- ក្នុងសិក្ខាសាលាកម្រិតបច្ចេកទេស(បន្ត) ស្តីពីយន្តការបញ្ជូនបន្តថ្នាក់ជាតិ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៦០នាក់ (ស្រី ២០នាក់) នៅខេត្តសៀមរាប។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. សន្និសីទ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អមដំណើរដោយ លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងសន្និសីទថ្នាក់តំបន់ ស្តីពីអំពើពុករលួយពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធជនទេសន្តប្រវេសន៍ ចំនួន២ថ្ងៃ នៅប្រទេសថៃ។

### ខ.២. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ខ.២.១ កិច្ចប្រជុំក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖ ១.កិច្ចប្រជុំពិភាក្សា និងកែសម្រួលបន្ត លិខិតបទដ្ឋានគតិយុត្តិ និងរចនាសម្ព័ន្ធ របស់ គ.ជ.ប.ជ។ ២.កិច្ចប្រជុំពិនិត្យ និងសម្រេចទម្រង់របាយការណ៍។ ៣.កិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីពិនិត្យទម្រង់របាយការណ៍ ដែលដាក់ចេញដោយក្រសួងមហាផ្ទៃ ដើម្បីត្រៀមរៀបចំរបាយការណ៍១០ខែ។ ៤.កិច្ចប្រជុំស្តីពី ការពង្រឹងភាពជាដៃគូ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយបណ្តាអង្គការដៃគូពាក់ព័ន្ធរួមមានអង្គការ (ERIKS JALPEN, CHAB DAI, CARITAS SWISS, CARITAS CAMBODIA, PLAN, IJM, UNDP, AIM, RATANAK, WINROCK, APLE, HAGAR, SAMARITAN's PURSE, CPU, ASEAN-ACT, LSCW, IOM, CWCC, ILO)។ ៥.កិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការមូលនិធិអេ២១ ដើម្បីពិនិត្យខ្សែភាពយន្តអប់រំ ក្រោមចំណងជើង តើអ្នកឃើញខ្ញុំទេ? ៦.កិច្ចប្រជុំចង្អៀតស្តីពី កិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ ដើម្បីត្រៀមឆ្លើយតបទៅនឹងអនុសាសន៍ របស់សហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការដាក់ចំណាត់ថ្នាក់ នៃការអនុវត្តផែនការសកម្មភាពប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ ៧.កិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការរៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស អ្នកចូលរួមចំនួន ១៩នាក់ (ស្រី ០៥នាក់)។ ៨.កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីការត្រៀមរៀបចំទិវាជាតិប្រឆាំងការជួញដូរអ្នកចូលរួមចំនួន ៤៣អង្គ/នាក់ (ស្រី ១៥នាក់)។ ៩.កិច្ចប្រជុំកម្រិតបច្ចេកទេស ពិនិត្យ និងឆ្លងរបាយការណ៍ ១០ខែ ឆ្នាំ២០២៣ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៤ និងឆ្លុះបញ្ចាំងផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ(២០១៩-២០២៣) អ្នកចូលរួមចំនួន ៩៧ នាក់ (ស្រី៥៧ នាក់)។
- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយអង្គការ IOM បានបើកកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិ ធ្វើការពិនិត្យ និងសម្រេចផែនការជាតិសម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដឹកនាំកិច្ចប្រជុំពិភាក្សាដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកស្រី គ្រីស្ទាន ផាកូ ប្រធានអង្គការ IOM សមាសភាពចូលរួមពីតំណាងក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ អង្គការដៃគូជាតិ និងអន្តរជាតិ សរុបចំនួន ៥៧នាក់។

### ១.២.២ កិច្ចប្រជុំក្រៅប្រទេស

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  - លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួម
    - ក្នុងកិច្ចប្រជុំ កម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ស្តីពីការសម្រេចសិទ្ធិ និងឱកាសរបស់ពលករទេសន្តរប្រវេសន៍ ជាស្ត្រី នៅក្នុងតំបន់អាស៊ាន (២០១៨-២០២៣) ចំនួន២ថ្ងៃ នៅប្រទេសថៃ រៀបចំដោយ អង្គការ UN Women គាំទ្រដោយសភាពអឺរ៉ុប EU និងអង្គការ ILO សមាសភាពចូលរួមពីបណ្តាប្រទេសមាន កម្ពុជា ថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន និងលេខាធិការដ្ឋានអាស៊ាន សរុបចំនួន ១០០នាក់។
    - កិច្ចប្រជុំកិច្ចពិភាក្សាតុមូល ស្តីពីតួនាទីនៃបច្ចេកវិទ្យា ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធជនចំណាកស្រុក នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន រៀបចំដោយស្ថាប័ន Regional SupportOffice (RSO) សហការជាមួយ Inter-Agency Council Against Trafficking (IACAT) ក្រោមជំនួយឧបត្ថម្ភរបស់ IOM មានអ្នកចូលរួមចំនួន ៦០នាក់។
  - ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការឆ្លងកាត់ព្រំដែន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ផ្នែសុខភាពជនទេសន្តរប្រវេសន៍ កម្ពុជា ថៃ ឡាវ នៅខេត្តអ៊ូប៊ុន ប្រទេសថៃ រៀបចំដោយអង្គការ IOM, UN Migration គាំទ្រដោយ អង្គការសុខភាពពិភពលោក និងក្រសួងសុខាភិបាលថៃ សរុបចំនួន ៨០នាក់។
  - ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារេត អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើចូលរួមវេទិកាអាស៊ានស្តីពី សិទ្ធិមនុស្សក្នុងលំហសមុទ្រ ជានាឱ្យមានការងារសមរម្យ ចំពោះពលករនេសាទ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដោយមានការចូលរួមពីបណ្តាប្រទេសក្នុងអាស៊ាន ដូចជាប្រទេសថៃ កម្ពុជា វៀតណាម ឡាវ មីយ៉ាន់ម៉ា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន តំណាង AICHR លេខាធិការអាស៊ាន វិស័យឯកជន ព្រមទាំងអង្គការ IOM និងIJM សរុបចំនួន ៤៦នាក់ (ស្រី ១៨នាក់)។

### ១.២. ការទទួលជួបពិភាក្សាការងារ

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយកិច្ចពិភាក្សាជាមួយ៖ ១.តំណាង អង្គការ IJM អំពីវគ្គបណ្តុះបណ្តាលបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពីការផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវរបស់អង្គការ IJM ២.តំណាងផ្នែកគោលនយោបាយ នៃស្ថានទូតអាមេរិក ប្រចាំនៅកម្ពុជា អំពីរបៀបវារៈដែលភាគីស្ថានទូតអាមេរិក ស្នើដាក់បញ្ចូលសម្រាប់កិច្ចប្រជុំ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានទូតអាមេរិក ស្តីពីរបាយការណ៍ប្រឆាំងការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក។ ៣.លោកជំទាវ Cyndy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់នៃសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការប្រឆាំងការជួញដូរមនុស្ស ដើម្បីសិក្សាបន្ថែមអំពីបទពិសោធន៍ការងារ របស់ គ.ជ.ប.ជ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ៤.លោកស្រី ONISHI AI លេខាទីមួយ និងជាប្រធានផ្នែកកិច្ចការនយោបាយ និងលោក Takahashi Katsutoshi លេខាទី២ នៃស្ថានទូតនៃព្រះរាជាណាចក្រជប៉ុន ដើម្បីពិភាក្សាអំពីវិធានការប្រឆាំងអំពើជួញដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា។ ៥.តំណាងអង្គការ

Rattanak International និងតំណាងអង្គការ IJM ចូលជួប និងគោរពជូនពរ ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២០២៤។ ៦.ឯកឧត្តមបណ្ឌិត Santo Darmosumarto អគ្គរដ្ឋទូតនៃស្ថានទូតឥណ្ឌូនេស៊ី ប្រចាំប្រទេសកម្ពុជា ស្តីពីកិច្ចប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងប្រទេសកម្ពុជា និងសាធារណរដ្ឋឥណ្ឌូនេស៊ី។

- លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នដែលជាសមាជិកនៃគ.ជ.ប.ជ ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ធ្វើឡើងក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាព នៃការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងការអនុវត្តអនុសាសន៍ របស់សហរដ្ឋអាមេរិកដែលបានដាក់ជូនមករាជរដ្ឋាភិបាលកម្ពុជា។
- **លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអនុញ្ញាតឱ្យទីប្រឹក្សាអង្គការ APLE លោក Mastair Hilton និងលោក **ផៃ សុភ័ក្រ** ជួបពិភាក្សាការងារទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើអ៊ីនធឺណិតរបស់កុមារ (OCSE) ដើម្បីបង្កើតគោលការណ៍ណែនាំបណ្តុះបណ្តាល សម្រាប់មន្ត្រីអនុវត្តច្បាប់ ដើម្បីដោះស្រាយករណី សម្ភារៈបំពានផ្លូវភេទលើកុមារ (CSAM) មុនពេលបញ្ចប់គម្រោងរបស់ APLE។

- **ខេត្តត្បូងឃ្មុំ៖**
  - មន្ត្រីជំនាញនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានជួបពិភាក្សាការងារជាមួយអង្គការក្តីសង្ឃឹមពិភពលោកអន្តរជាតិ ស្តីពីការវាយតម្លៃគម្រោងពង្រឹងប្រព័ន្ធដែលផ្តោតសំខាន់ទៅលើការកសាងសមត្ថភាព របស់អ្នកពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការស្វែងយល់បន្ថែមទៀតពីតម្រូវការ ដើម្បីដាក់ចូលក្នុងគម្រោងក្នុងឆ្នាំ២០២៤។
  - លោកជំទាវ អភិបាលរងខេត្ត បានដឹកនាំក្រុមលេខាធិការដ្ឋាន និងក្រុមការងារជំនាញទាំង ០៦ ជួបពិភាក្សាការងារជាមួយអង្គការណ្ឌូមីណោតវើក ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
  - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងលោកស្រីស្នងការរងនគរបាលខេត្ត បានជួបពិភាក្សាជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងអង្គការណ្ឌូវើណោតវើក ដើម្បីពិភាក្សាអំពីការងារទូទៅពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការងារយេនឌ័រ ស្ត្រីនិងកុមារ។

## គ. ការងារសម្របសម្រួល

សមាជិកនៃគ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ សម្របសម្រួល និងរៀបចំកិច្ចប្រជុំដើម្បីព្រងឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធ សរុបចំនួន **២៣១**លើក មានអ្នកចូលរួមចំនួន **៤.៦៧០**នាក់ (ស្រី **១.៥៧២**នាក់) មាន៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **៥៣**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **២៨៤**លើក។(**ឧបសម្ព័ន្ធ១**)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅត្រីមាសទី១ ឆ្នាំ ២០២៤

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង

ទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៩. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១០. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.ច័ន្ទ...១១រោច...ខែ.អាសាឍ...ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី...៥...ខែ.កក្កដា...ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជួ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ២៨៤លើក) មនុស្សចំនួន ៤.៦៧០នាក់ (ស្រី ១.៥៧២នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.បានអញ្ជើញចូលរួម ជាអធិបតីក្នុង៖<br>- សិក្ខាសាលាស្តីពី តួនាទីនៃវិស័យវប្បធម៌ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំដោយក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីពិនិត្រនិងពង្រឹងឡើងវិញចំពោះរចនាសម្ព័ន្ធ តួនាទីភារកិច្ចវិស័យវប្បធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងអាណត្តិរដ្ឋាភិបាលនីតិកាលទី៧។<br>- ពិធីប្រកាសឱ្យអនុវត្តគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តប្រវេស ឆ្នាំ២០២២-២០៣០ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។<br>- ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**។<br>- ទិវាអន្តរជាតិទេសន្តរប្រវេសន៍ករ ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- ដឹកកិច្ចប្រជុំ ស្តីពីការបែងចែកភារកិច្ច សម្រាប់ការរៀបចំទិវាជាតិ ១២ធ្នូ ២០២៣ ជាមួយក្រុមពិធីការក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។<br>- សិក្ខាសាលាស្តីពី តួនាទីនៃវិស័យវប្បធម៌ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំដោយក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីពិនិត្រនិងពង្រឹងឡើងវិញចំពោះរចនាសម្ព័ន្ធ តួនាទីភារកិច្ចវិស័យវប្បធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងអាណត្តិរដ្ឋាភិបាលនីតិកាលទី៧។<br>- អមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ពិធីប្រកាសឱ្យអនុវត្តគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តប្រវេស ឆ្នាំ២០២២-២០៣០ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។<br>- បើកកម្មវិធី ការចាប់ផ្តើមដំណើរការគម្រោងការពង្រឹងការការពារ និងផ្តល់សេវាកម្មដល់ជនរងគ្រោះ ដែលរៀបចំឡើងដោយ អង្គការ IOM, UN Migration ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារ Sun &Moon។ |

| | |
|---|---|
| | ▪ អមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ព្រមទាំងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។**<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១០៨ច្បាប់ លិខិតចូល ៩០ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៦០ច្បាប់ លិខិតចូល ៧៥ច្បាប់។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគីចំនួន បានចំនួន ១២៤ច្បាប់។។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ២០៩ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ៧០សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ៦៧ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញ<br>○ ដឹកនាំប្រជុំក្រុមការងារព័ត៌មានវិទ្យា រូបភាព បទយកការណ៍ និងផ្សព្វផ្សាយ ដើម្បីត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ។<br>○ ចូលរួមសិក្ខាសាលាកម្រិតខ្ពស់ស្តីពី ការពិនិត្យ និងឯកភាពលើកម្មវិធីកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការ Unicef សម្រាប់ឆ្នាំ ២០២៤-២០២៨ ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ អ្នកចូលរួមចំមនួន **១១១**នាក់ នៅសណ្ឋាគារសូហ្វីតែលភូគីត្រា ភ្នំពេញ។<br>○ ចូលរួមកិច្ចប្រជុំផ្តល់ធាតុចូល ស្តីពី «ការពង្រឹងគោលនយោបាយ ភូមិឃុំសង្កាត់មានសុវត្ថិភាព ដោយផ្តោតការយកចិត្តទុកដាក់ពិសេសការកាត់បន្ថយបញ្ហាគ្រឿងញៀន និងការជួញដូរមនុស្ស នៅក្នុងសហគមន៍» អ្នកចូលរួមចំនួន**០៧**នាក់។<br>- លោកប្រធានក្រុម បានចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តគម្រោងគាំទ្រ និងការពារជនរងគ្រោះរួចផុតជីវិតដោយអំពើជួញដូរមនុស្ស រួមទាំងការបោកបញ្ឆោតតាមប្រព័ន្ធអនឡាញនៅកម្ពុជា រៀបចំដោយអង្គការការីតាសកម្ពុជា។<br>- បានចូលរួមសិក្ខាសាលាស្តីពី ការពង្រឹងអក្ខរាវិរុទ្ធខ្មែរ ក្រមសីលធម៌នៅលើវេទិកា ឬផ្សាយផ្ទាល់ និងស្វែងយល់ពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងគ្រឿងញៀន ដែលរៀបចំដោយក្រសួងព័ត៌មាន នៅទីស្តីការក្រសួងព័ត៌មាន អ្នកចូលរួមចំនួន**២៩៨**នាក់។<br>- បានចូលរួមជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តប៉ៃលិន។ |

| | |
|---|---|
| | - បានចូលរួមសិក្ខាសាលាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរៀបចំដោយក្រុមការងារចំពោះកិច្ចអន្តរស្ថាប័នប្រឆាំងការជួញដូរមនុស្ស សិង្ហបុរី (SINGAPORE INTER-AGENCY TASKFORCE ON TRAFFICKING IN PERSON) ក្រោមកិច្ចសហការគាំទ្រដោយកម្មវិធីបណ្តុះបណ្តាលប្រទេសទី៣ ក្រៅពីសិង្ហបុរី និងសហរដ្ឋអាមេរិក (SINGAPORE-UNITED STATES THIRD COUNTRY TRAINNING PROGRAMME) នៅប្រទេសសិង្ហបុរី។<br>- បានចូលរួមយុទ្ធនាការស្តីពី សុវត្ថិភាពអនឡាញសម្រាប់កុមារី និងយុវតី រៀបចំដោយអង្គការសេរីភាពកម្ពុជាអូស្ត្រាលី នៅសាលារៀនចំរើនផល អ្នកចូលរួមចំនួន**៤០០**នាក់ ស្រី**៣០០**នាក់។<br>- បានសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) ជំរុញក្រុមហ៊ុនទូរស័ព្ទ ឱ្យបញ្ជូនសារអប់រំ (SMS) ទៅកាន់ទូរស័ព្ទចល័ត ដើម្បីចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣ ដែលមានខ្លឹមសារ «បច្ចេកវិទ្យាជាមធ្យោបាយដើម្បីអភិវឌ្ឍជាតិ មិនមែនដើម្បីជួញដូរមនុស្ស»។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់គោលនយោបាយស្តីពី ការលើកកម្ពស់ការប្រើប្រាស់យន្តការ ទទួលពាក្យបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍គ្រប់រូប ដែលរៀបចំដោយអង្គការ SLCW ក្រោមជំនួយគាំទ្ររបស់ DFAT និង GAC តាមរយៈគម្រោងត្រីកោណអាស៊ានរបស់ ILO ក្រោមអធិបតីភាពឯកឧត្តម **ហូ វុទ្ធី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារភ្នំពេញ អ្នកចូលរួមចំនួន**៤៧**នាក់ ស្រី**២៥**នាក់។<br>- បានចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលស្តីពី បែបបទនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលរៀបចំដោយ គ.ជ.ប.ជ នៅខេត្តរតនៈគិរី។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម<br>○ វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តញាណជនរងគ្រោះដោយអំពើជួញដូមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពត។<br>○ ពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តប៉ៃលិន។<br>○ កិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ជាសកល សម្រាប់ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ។<br>○ កិច្ចប្រជុំពិភាក្សាកែសម្រួលលើរបៀបវារៈ នៃការដាក់ឱ្យប្រើប្រាស់សៀវភៅគោលនយោបាយជាតិស្តីពី សុខភាពជនទេសន្តប្រវេសន៍ នៅក្រសួងសុខាភិបាល។<br>○ ធ្វើគ្រូឧទ្ទេសដល់មន្ត្រីជួរមុខស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តស្ទឹងត្រែង។<br>○ កម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ទេសន្តប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្សនៅអាស៊ី នៅខេត្តសៀមរាប។<br>○ កិច្ចប្រជុំពិភាក្សាត្រៀមរៀបចំកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះ ប៉ោយប៉ែត នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>○ កិច្ចប្រជុំកែសម្រួល និងរកជាតុចូល នៃកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ថៃ ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកនីតិវិធីអនុវត្តស្តង់ដារ (SOP)នៅខេត្តសៀមរាប។ |

- កិច្ចប្រជុំតាមប្រព័ន្ធ ZOOM ស្តីពីកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាព និងសុខាភិបាល សម្រាប់ការសម្ពោធដាក់ឲ្យប្រើប្រាស់ មណ្ឌលសំចត និងស្តារយុវនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត។
- កិច្ចប្រជុំ អនុគណៈកម្មការសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាព និងសុខាភិបាល ដើម្បីរក្សាសុខសុវត្ថិភាព ជូនគណៈប្រតិភូអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត នៅមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

- បានចូលរួមធ្វើគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។

**▪ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម
  - កិច្ចប្រជុំលើកទី១៣ របស់ក្រុមការងារស្តីពី ការជួញដូរមនុស្សនៃសន្និសីទរដ្ឋភាគីនៃអនុសញ្ញា អ.ស.ប ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រារព្ធឡើងនៅទីក្រុងវីយែន ប្រទេសអូទ្រីស ក្នុងទម្រង់ Hybrid ជាភាសាអង់គ្លេស។
  - កិច្ចប្រជុំពិភាក្សាពិនិត្យលើ អនុស្សរណៈ MOU on Strengthening the National System for Addressing and Preventing Gender-Based Violence (GBV) ដែលត្រូវបានរៀបចំដោយ ក្រសួងកិច្ចការនារី និង ADB ។
  - កិច្ចពិភាក្សាជាមួយតំណាងអង្គការ IJM អំពីវគ្គបណ្តុះបណ្តាលបែបបទនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពីការផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវរបស់អង្គការ IJM ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
  - កិច្ចប្រជុំ ស្តីពីវឌ្ឍនភាព បញ្ហាប្រឈម និងពិភាក្សាអំពីការអនុវត្តបន្ត នៃអនុសាសន៍របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសិទ្ធិមនុស្ស រៀបចំដោយ CNCC & UNICEF នៅសណ្ឋាគារ កាំបូឌីយ៉ាណា។
  - កិច្ចប្រជុំស្តីពីការបែងចែកភារកិច្ច សម្រាប់ការរៀបចំទិវាជាតិ ១២ធ្នូ ២០២៣ ជាមួយក្រុមពិធីការក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។
  - កិច្ចពិភាក្សា និងជួបសម្ភាសន៍ ជាមួយទីប្រឹក្សាមកពីអង្គការ APLE លោក Mastair Hilton ទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើអ៊ីនធឺណិត របស់កុមារ (OCSE) ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។
  - កិច្ចប្រជុំបន្ត និងបញ្ចប់ លើការពិនិត្យ និងពិភាក្សាបន្តលើសេចក្តីព្រាងអនុស្សារណៈ នៃការយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា នៅទីស្តីការក្រសួងមហាផ្ទៃ។
  - កិច្ចពិភាក្សា គោលដៅអំពីការផ្តល់ជំនួយផ្នែកច្បាប់សម្រាប់ករណីជួញដូរមនុស្ស ក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ាន ដែលសម្របសម្រួលដោយអង្គការ ASEAN-ACT តាមរយៈប្រព័ន្ធវីដេអូហ្សូម។

| | |
|---|---|
| | ○ កិច្ចប្រជុំផ្ទៃក្នុងបូកសរុបការងាររបស់ក្រុមការងារ SOMTC-កម្ពុជា និងលើកទិសដៅការងារបន្ត នៅសាលប្រជុំខេត្តសៀមរាប ទីស្តីការក្រសួងមហាផ្ទៃ។<br>○ សិក្ខាសាលាពិគ្រោះយោបល់ស្តីពី នីតិវិធីស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្ទៀងផ្ទាត់ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលរៀបចំដោយក្រុមការងារខមមីតវៀតណាម នៅសណ្ឋាគារ Le Casa នាទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម អ្នកចូលរួមចំនួន៤៣នាក់។<br>- លោកប្រធានក្រុម បានចូលរួមកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (RTF) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១៥ (SOM15)។<br>- លោកស្រីអនុប្រធានក្រុម បានចូលរួមកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីទេសន្តរប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្សនៅអាស៊ី នៅខេត្តសៀមរាប។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញ<br>○ ដឹកនាំក្រុមការងារ ចុះបំពេញបេសកកម្មពិនិត្យឧបករណ៍ សម្ភារៈសោតទស្សន៍ កុំព្យូទ័រ និងម៉ាស៊ីនបញ្ចាំងស្លាយ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។<br>○ ជាគណៈអធិបតី ក្នុងកម្មវិធីបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីទេសន្តរប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្សនៅអាស៊ី ខេត្តសៀមរាប។<br>○ ពិធីប្រកាសឱ្យអនុវត្តគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តប្រវេស ឆ្នាំ២០២២-២០៣០ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។<br>- បានចូលរួមប្រជុំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០២៤-២០២៨) ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- បានចូលរួមប្រជុំស្តីពីការពង្រឹងភាពជាដៃគូក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។<br>- បានចូលរួមពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអាណត្តិទី១ និងលើកទិសដៅការងារបន្ត របស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម (គ.ជ.ប.ទ) ក្រោមអធិបតីភាពឯកឧត្តម **នុត សាអាន** ប្រធាន គ.ជ.ប.ទ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមរៀបចំ និងបើកវគ្គបណ្តុះបណ្តាលស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របដល់មន្ត្រីពាក់ព័ន្ធជួរមុខក្នុងខេត្តកំពត និងខេត្តប៉ៃលិន។<br>- បានអមដំណើរលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមកម្មវិធី ព្យុហយាត្រាឆ្ពោះទៅបញ្ឈប់អំពើជួញដូរមនុស្ស លើកទី២ ឆ្នាំ២០២៣ ដែលរៀបចំដោយរដ្ឋបាល ខេត្តសៀមរាប សហការគាំទ្រដោយអង្គការមូលនិធិអេ២១។ |

| | |
|---|---|
| | - បានចូលរួមសហការជាមួយលេខាធិការដ្ឋានរដ្ឋបាល សរុប ក្នុងការរៀបចំ និងបើកវគ្គបណ្តុះបណ្តាលស្តីពី តួនាទីភារកិច្ច និងរបៀបរបបការងារ ក្នុងរចនាសម្ព័ន្ធនៅខេត្តប៉ៃលិន ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។<br>- បានជួបពិភាក្សាជាមួយតំណាងអង្គការ IJM អំពីការរៀបចំផែនការបើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលត្រៀមធ្វើនៅ ខេត្តបាត់ដំបង ឧត្តរមានជ័យ និងកោះកុង នាពេលមុខនេះ។<br>- បានចូលរួមប្រជុំ ស្តីពីការឆ្លងកាត់ព្រំដែន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ផ្នែកសុខភាពជនទេសន្តរប្រវេសន៍ កម្ពុជា ថៃ ឡាវ នៅខេត្តអ៊ូប៊ុន ប្រទេសថៃ រៀបចំដោយអង្គការ IOM, UN Migration គាំទ្រដោយអង្គការសុខភាពពិភពលោក និងក្រសួងសុខាភិបាលថៃ។<br>- បានចូលរួមធ្វើផែនការ និងរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី បែបបទ និងនីតិវិធី ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តរតនគិរី និងខេត្តឧត្តរមានជ័យ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់គោលនយោបាយស្តីពី ការលើកកម្ពស់ការប្រើប្រាស់យន្តការ ទទួលពាក្យបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍គ្រប់រូប ដែលរៀបចំដោយអង្គការ SLCW ក្រោមជំនួយគាំទ្ររបស់ DFAT និង GAC តាមរយៈគម្រោងត្រីកោណអាស៊ានរបស់ ILO ក្រោមអធិបតីភាពឯកឧត្តម **ហូ វុទ្ធី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារភ្នំពេញ។<br>- បានចូលរួមទិវាអន្តរជាតិទេសន្តរប្រវេសន៍ ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម<br>○ វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រយៈពេលបីថ្ងៃនៅខេត្តកំពត។<br>○ អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមទិវាអន្តរជាតិទេសន្តរប្រវេសន៍ ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៣១លើក អ្នកចូលរួមសរុបចំនួន ២.៩៧៩នាក់ (ស្រី ១.២២៩នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែ និងត្រីមាសទី៤ចំនួន ០៣លើក អ្នកចូលរួមចំនួន**២៧១**នាក់ ស្រី**១៤៣**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែចំនួន**២០**លើក អ្នកចូលរួមចំនួន**៤៦០**នាក់ ស្រី**៥២២**នាក់។ |
| **ខេត្តត្បូងឃ្មុំ** | - មន្ត្រីជំនាញ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចូលរួមកិច្ចប្រជុំស្តីពី លទ្ធផលស្រាវជ្រាវលើគម្រោងបង្កើនសមត្ថភាពមន្ត្រីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលរៀបចំ JICA ចំនួន**០១**លើក នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |

| | |
|---|---|
| **ខេត្តពោធិ៍សាត់** | - បានរៀបចំកិច្ចប្រជុំពិភាក្សាលើផែនការការងារ ជាមួយអង្គការដៃគូ ចំនួន០១លើក។<br>- បានប្រជុំផ្សព្វផ្សាយសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តចំនួន ០១លើក។ |
| **ខេត្តព្រៃវែង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយសមាគមន៍នារីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងអនាម័យចំនួន ០១លើក។<br>- រដ្ឋបាលខេត្ត បានរៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ដើម្បីពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ ផ្សព្វផ្សាយការងារភូមិ-ឃុំ មានសុវត្ថិភាព ចំនួន០១លើក អ្នកចូលរួមចំនួន១០៣នាក់។<br>- រដ្ឋបាលខេត្តបានរៀបចំកិច្ចប្រជុំជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **ចាន់ អ៊ាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន៤០៥នាក់។ |
| **ខេត្តសៀមរាប** | - ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ ចំនួន០៩លើក អ្នកចូលរួមចំនួន២០២នាក់ ស្រី១០២នាក់។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន០១លើក។<br>- បានចូលរួមក្នុងពិធីកិច្ចពិភាក្សាស្តីពី បញ្ហាប្រឈមរបស់ពលករចំណាកស្រុក ទាក់ទងនឹងអំពើហិង្សាផ្អែកលើយ៉េនឌ័រ ក្រោមការសម្របសម្រួលដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រីចំនួន០១លើក អ្នកចូលរួមចំនួន២៩នាក់ ស្រី២០នាក់។ |
| **ខេត្តស្វាយរៀង** | - បានចូលរួមសិក្ខាសាលាស្តីពី យន្តការបញ្ជូនបន្តថ្នាក់ជាតិពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារកាំបូឌីយ៉ាណារាជធានីភ្នំពេញ ចំនួន០១លើក អ្នកចូលរួមចំនួន៦០នាក់ ស្រី៣៥នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ជួញដូរមនុស្ស នៅសាលា (ILEA) ប្រទេសថៃ ចំនួន០១លើក អ្នកចូលរួមចំនួន៤៨នាក់។ |
| **ខេត្តតាកែវ** | - ឯកឧត្តមអភិបាលខេត្ត និងអភិបាលរងខេត្ត បានដឹកនាំកិច្ចប្រជុំ ពិភាក្សាការងារប្រចាំថ្ងៃ និងចូលរួមសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមប្រព័ន្ធអនឡាញ និងអញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ មេប៉ុស្តិ៍ នាយកសាលា មណ្ឌលសុខភាព ក្នុងនោះក៏បានបញ្ជ្រាបការងារជួញដូរស្ត្រី និងកុមារចំនួន ១៤០លើក អ្នកចូលរួមសរុបចំនួន៤៥៧នាក់ ស្រី៣០២នាក់។<br>- តំណាងមន្ទីរកិច្ចការនារី បានចូលរួមសិក្ខាសាលាគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តកំពតចំនួន០១លើក អ្នកចូលរួមចំនួន៤២នាក់ស្រី៣០នាក់។ |
| **ខេត្តបន្ទាយមានជ័យ** | - បានចូលរួមប្រជុំពិភាក្សាការងារជាមួយភាគីថៃ ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមទាក់ទងការសម្របសម្រួលដំណើរចេញ-ចូល របស់ប្រជាពលករខ្មែរតាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត-ខ្លងលឹក។<br>- លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌល បានចូលរួមសម្របសម្រួលចំនួន០២លើក លើការងារប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស អំពីលទ្ធផលស្រាវជ្រាវគម្រោងបង្កើនសមត្ថភាពមន្ត្រី និងប្រព័ន្ធបញ្ជូនជនរងគ្រោះថ្នាក់ជាតិ ដែលរៀបចំដោយ គ.ជ.ប.ជ នៅរាជធានីភ្នំពេញ។ |

| | |
|---|---|
| | - លោកស្រីឧត្តមសេនីយ៍ត្រី ស្នងការរង បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអនឡាញ ចំនួន០១លើក។<br>- បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ ព្រមទាំងបានលើកឡើងពីវិធានការទប់ស្កាត់ ការធ្វើចំណាកស្រុកដោយខុសច្បាប់ និងសម្របសម្រួលនីតិវិធីឆ្លងដែនតាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រទ្វារតំបន់ទ្វេភាគី។<br>- បានប្រជុំបូកសរុបលទ្ធផលការងារអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ជាមួយក្រុមការងារ និងអង្គភាពពាក់ព័ន្ធក្នុងខេត្ត។<br>- ក្រុមការងារគ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាក ស្រុកដោយប្រថុយប្រថាន។ |
| **ខេត្តមណ្ឌលគិរី** | - ប្រធានលេខាធិការដ្ឋាន បានចូលរួមប្រជុំកិច្ចសហប្រតិបត្តិការការងារគណៈចលនាមហាជន រវាងខេត្តមណ្ឌលគិរី និងខេត្តដាក់ណុង ប្រទេសវៀតណាម ដើម្បីរឹតចំណងការកសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព ពិសេសបន្តរួមគ្នាផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ និងបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ។<br>- បានសហការ និងចូលរួមវគ្គបណ្តុះបណ្តាលស្តីពី តួនាទី ភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ គ.ខ.ប.ជ ដែលរៀបចំដោយ គ.ជ.ប.ជ ចំនួន០១លើក ។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំប្រចាំខែស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ០៣លើក។<br>- រដ្ឋបាលស្រុក បានរៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាព ដើម្បីពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ និងផ្សព្វផ្សាយច្បាប់ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន០៣លើក អ្នកចូលរួមចំនួន៨២លើក ស្រី២៤នាក់។<br>- បានចូលរួមវគ្គប៉ប៉នសមត្ថភាពស្តីពី នីតិវិធីកសាងសំណុំរឿង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន០១លើក អ្នកចូលរួមចំនួន៧៣នាក់ ស្រី១១នាក់។<br>- បានចូលរួមកិច្ចប្រជុំស្តីពី តួនាទីភារកិច្ចមន្ត្រីនគរបាលយុត្តិធម៌ទាក់ទងនឹងការស៊ើបអង្កេតអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ អ្នកចូលរួមចំនួន៦៣នាក់ ស្រី២០នាក់។ |
| **ខេត្តមណ្ឌលគិរី** | - បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពីការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តកំពតចំនួន០១លើក។ |
| **ខេត្តកំពត** | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធចំនួន០១លើក អ្នកចូលរួមចំនួន២៩នាក់ ស្រី១៥នាក់។<br>- បានរៀបចំកិច្ចប្រជុំប្រចាំខែ និងបូកសរុបលទ្ធផលការងារប្រចាំឆ្នាំចំនួន០១លើក អ្នកចូលរួមចំនួន៣០នាក់ ស្រី១៥នាក់។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមជាអធិបតីបើកវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យចំនួន០២លើក នៅស្រុកសំឡូត និងស្រុកបវេល។ |

| | |
|---|---|
| | - បានចូលរួមផ្សព្វផ្សាយជាមួយមណ្ឌលទទួលពលករកំរៀង អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅមូលដ្ឋានព្រមទាំងណែនាំដល់ពលរដ្ឋដែលរងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម វិវាទការងារទេសន្តរប្រវេសន៍ មកដាក់ពាក្យបណ្ដឹង និងប្រឹក្សាយោបល់នៅមណ្ឌលទទួលពលករកំរៀងចំនួន **០៣**លើក នៅឃុំតាគ្រាំ ស្រុកកំរៀង អ្នកចូលរួមចំនួន**១៣៦**នាក់ ស្រី**៨៣**នាក់។<br>- បានចូលរួមកិច្ចប្រជុំត្រីមាសទី៤ ជាមួយអ្នកពាក់ព័ន្ធរបស់មណ្ឌលទទួលពលករកំរៀងស្ដីពី "វឌ្ឍនភាពរបស់មណ្ឌល និងបង្កើតកិច្ចសហប្រតិបត្តិការ" ដោយមានការគាំទ្រថវិកាពីអង្គការការីតាស់ស្វីស នៅស្រុកកំរៀង អ្នកចូលរួមចំនួន**៤៤**នាក់ ស្រី**១៤**នាក់។<br>- បានចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោងស្ដីពី ការពិនិត្យ និងរៀបចំផែនការសកម្មភាពបន្ត សម្រាប់អនុវត្តគម្រោង ILO-TRIANGLE ឆ្នាំ២០២៤ នៅសណ្ឋាគារភ្នំពេញ។ |
| **ខេត្តស្ទឹងត្រែង** | - បានសហការ និងចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី តួនាទី ភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ គ.ខ.ប.ជ ដែលរៀបចំដោយ គ.ជ.ប.ជ ចំនួន**០១**លើក ។ |
| **ខេត្តប៉ៃលិន** | - លោកស្រី អភិបាលរងខេត្ត បានចូលរួមជាគណៈធិបតី បើកវគ្គបណ្ដុះបណ្ដាលស្ដីពី បែបបទនីតិវិធី និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប និងជាគណៈអធិបតី បើកវគ្គបណ្ដុះបណ្ដាល ពង្រឹងសមត្ថភាពមន្ត្រី ស្ដីពីតួនាទី ភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ ដែលរៀបចំដោយ គ.ជ.ប.ជ សរុបចំនួន**០២**លើក ធ្វើនៅខេត្តប៉ៃលិន។ |